ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
លេខៈ ៣០១ គ.ជ.ប

# សេចក្តីណែនាំ
## ស្តីពី
## កិច្ចសហការការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈសម្រាប់ដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤ នៅថ្ងៃអាទិត្យ ទី០៤ ខែមិថុនា ឆ្នាំ២០១៧

ដើម្បីធានាបាននូវសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ និងបរិយាកាសនយោបាយល្អ ស្ងប់ស្ងាត់ អព្យាក្រឹត និងយុត្តិធម៌ក្នុងការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤ ឆ្នាំ២០១៧ នេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) សូមណែនាំដល់លោក លោកស្រី ប្រធានគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប) ដូចខាងក្រោម ៖

១- បន្តពង្រឹង និងជំរុញកិច្ចសហការឲ្យកាន់តែខ្លាំងក្លាថែមទៀតជាមួយនឹងគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលជាគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីផ្លាស់ប្តូរព័ត៌មានពាក់ព័ន្ធការងារសន្តិសុខ និងចាត់វិធានការអនុវត្តតាមគោលការណ៍ដែលបានកំណត់នៅក្នុងផែនការអន្តរស្ថាប័នលេខ ០០៩ ជ.ក/១៦ របស់ក្រសួងមហាផ្ទៃ-ក្រសួងការពារជាតិ និង គ.ជ.ប ស្តីពីកិច្ចការពារការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មីឆ្នាំ២០១៦ ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងការបោះឆ្នោតថ្នាក់ជាតិ-ថ្នាក់ក្រោមជាតិ ចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៩ ។

២- ត្រូវសហការចាត់វិធានការរក្សាការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ សម្រាប់គ្រប់សកម្មភាពរបស់ភ្នាក់ងារ និងបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ប្រជាពលរដ្ឋដែលអញ្ជើញទៅបោះឆ្នោត អ្នកសង្កេតការណ៍ជាតិ អន្តរជាតិ ដែលត្រូវចូលរួមក្នុងដំណើរការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤ ឆ្នាំ២០១៧ ឲ្យបានមធ្យ័តបំផុតតាមសមត្ថកិច្ចដែនដីរបស់ខ្លួន ។

៣- ត្រូវយកចិត្តទុកដាក់សហការក្នុងការរៀបចំកម្លាំងភ្នាក់ងារសន្តិសុខបោះឆ្នោត និងចាត់វិធានការការពារសន្តិសុខ រក្សាសុវត្ថិភាព សម្រាប់មុខសញ្ញា និងគោលដៅសំខាន់ៗដែលត្រូវការពារជាអាទិភាព រួមមាន ៖

ក. មុខសញ្ញាការពារជាអាទិភាព

- សមាជិក សមាជិកា គ.ជ.ប និងមន្ត្រីបោះឆ្នោតគ្រប់ជាន់ថ្នាក់របស់ គ.ជ.ប
- គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត បេក្ខជន និងអ្នកគាំទ្រ
- ប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោត
- អ្នកសង្កេតការណ៍បោះឆ្នោតនៃសមាគម អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ តំណាង ឬភ្នាក់ងារគណបក្សនយោបាយ ដែលទទួលបានការអនុញ្ញាត
- តំណាងរបស់អង្គការក្រៅរដ្ឋាភិបាលបរទេស ឬប្រទេសនានា និងតំណាងអង្គការអន្តរជាតិ ដែលត្រូវបាន គ.ជ.ប អញ្ជើញឱ្យចូលរួមជាអ្នកសង្កេតការណ៍។

ខ. គោលដៅការពារជាអាទិភាព

- ទីស្តីការ គ.ជ.ប និងទីស្នាក់ការ គច.ខប និង គឃ.សប
- ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត
- ទីតាំងបិទផ្សាយបញ្ជីបោះឆ្នោត បញ្ជីទីតាំងការិយាល័យបោះឆ្នោត បញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត
- ទីតាំងរោងពុម្ពផលិតសន្លឹកឆ្នោត
- កន្លែងរក្សាទុក ឬការដឹកជញ្ជូនសម្ភារ បរិក្ខារ និងសង្ហារឹមបម្រើការងារបោះឆ្នោត ឯកសារបោះឆ្នោត សន្លឹកឆ្នោត និងកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតពីគោលដៅមួយទៅគោលដៅមួយ ដែលកំណត់ដោយ គ.ជ.ប ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់
- ទីស្នាក់ការ និងកន្លែងជួបប្រជុំ ឬក្បួនព្យុហយាត្រាឃោសនារបស់គណបក្សនយោបាយ ឬបេក្ខជន។

៤- ត្រូវទទួលខុសត្រូវ និងចាត់ចែងស្នើសុំអន្តរាគមន៍ពីកម្លាំងមានសមត្ថកិច្ច ពិសេសភ្នាក់ងារសន្តិសុខបោះឆ្នោត ក្នុងករណីមានជនបង្កការអុកឡុក រំខាន គំរាមកំហែង ឬការប្រព្រឹត្តអំពើល្មើសច្បាប់ផ្សេងៗ ធ្វើឲ្យរាំងស្ទះដល់សកម្មភាពនៃដំណើរការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ សម្រាប់ឈរឈ្មោះបោះឆ្នោត ដំណើរការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងដំណើរការបោះឆ្នោត និងរាប់សន្លឹកឆ្នោត។

៥- ត្រូវចាត់ចែងរៀបចំកិច្ចប្រជុំចម្រុះ ក្នុងគោលដៅជួបពិភាក្សា និងស្វែងរកដំណោះស្រាយសមស្រប រួមនឹងការចាត់វិធានការផ្សេងៗ ដើម្បីបង្ការ ទប់ស្កាត់ និងកាត់បន្ថយឱ្យបានរាល់បញ្ហាទំនាស់ ឬក៏បាតុភាពនានា ដែលអាចនឹងកើតមានឡើងជាយថាហេតុនៅគ្រប់ដំណាក់កាលនៃការរៀបចំការបោះឆ្នោត ។ កិច្ចប្រជុំត្រូវរៀបចំប្រជុំ ម្តងក្នុងមួយសប្តាហ៍ និងអាចកោះប្រជុំតាមការចាំបាច់ ។

សមាសភាពចូលរួមក្នុងកិច្ចប្រជុំនេះ រួមមាន ៖

- ប្រធាន គធ.ខប ជាប្រធាន
- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ឬតំណាង ០១រូប ជាសមាជិក
- តំណាង០១រូបៗ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងរាជធានី ខេត្ត ជាសមាជិក
- តំណាង ០១រូបៗ អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិក្នុងរាជធានី ខេត្ត ជាសមាជិក
- ស្នងការនគរបាលរាជធានី ខេត្ត ឬតំណាង ០១រូប ជាសមាជិក
- មេបញ្ជាការកងរាជអាវុធហត្ថរាជធានី ខេត្ត ឬតំណាង ០១រូប ជាសមាជិក
- មេបញ្ជាការយោធភូមិភាគពិសេស ឬយោធភូមិភាគទី ១-៥ ក្នុងរាជធានី ខេត្ត ពាក់ព័ន្ធ ឬតំណាង ០១ រូប ជាសមាជិក
- មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងរាជធានី ខេត្ត ឬតំណាង ០១រូប ជាសមាជិក

ទទួលបាននូវសេចក្តីណែនាំនេះ សូមអស់លោក លោកស្រី ប្រធាន គធ.ខប យកចិត្តទុកដាក់អនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ២០១៧

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

**ស៊ិក ប៊ុនហុក**

**ចម្លងជូន :**

- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- លេខាធិការដ្ឋាន នៃគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍
- អគ្គស្នងការដ្ឋាននគរបាលជាតិ
- គណៈអភិបាល និងជាគណៈបញ្ជាការឯកភាពរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- លេខាធិការដ្ឋានសន្តិសុខបោះឆ្នោត គ.ជ.ប
- ឯកសារ-កាលប្បវត្តិ